ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ......៥៧៧......អពដ

រាជធានីភ្នំពេញ,ថ្ងៃទី ១១ ខែមេសា ឆ្នាំ២០១៤

# សេចក្តីជូនដំណឹង
## ស្តីពី
## កាលបរិច្ឆេទកំណត់ឲ្យដាក់លិខិតប្រកាសពន្ធ ឬបង់ប្រាក់ពន្ធ ប្រចាំខែមេសា ឆ្នាំ២០១៤

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកិត្តយស សូមជម្រាបជូនដំណឹងដល់អ្នកជាប់ពន្ធ និងសាធារណជនទាំងអស់ឲ្យបានជ្រាបថា សម្រាប់ការដាក់លិខិតប្រកាស ឬបង់ប្រាក់ពន្ធប្រចាំខែមេសា ឆ្នាំ២០១៤ ដែលត្រូវចំថ្ងៃប្រារព្ធពិធីបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ គឺជាថ្ងៃឈប់សម្រាកស្របតាមប្រតិទិនឈប់សម្រាកការងារ របស់មន្ត្រីរាជការ និយោជិត កម្មករ នៅព្រះរាជាណាចក្រកម្ពុជា កាលបរិច្ឆេទកំណត់ឲ្យដាក់លិខិតប្រកាសពន្ធ ឬបង់ប្រាក់ពន្ធប្រចាំខែគ្រប់ប្រភេទ រួមទាំងអាករលើតម្លៃបន្ថែម នឹងត្រូវអនុញ្ញាតពន្យាពេលរហូតដល់ថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៤ ។ សម្រាប់ខែបន្តបន្ទាប់ត្រូវអនុវត្តជាធម្មតាដូចមានចែងក្នុងលិខិតជូនដំណឹងលេខ ១០៨៧ អពដ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ។

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សង្ឃឹមជឿជាក់ថា ការកំណត់កាលបរិច្ឆេទដាក់លិខិតប្រកាស និងបង់ពន្ធនេះ នឹងជួយសម្រួលដល់អ្នកជាប់ពន្ធទាំងអស់ ក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធដាក់ជាពុំខាន ។

ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ
អគ្គនាយករង
គុំ សីហា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានពន្ធដារ
នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ......១០៨៧......អពដ

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ ២០១៣

# សេចក្តីជូនដំណឹង
## ស្តីពី
## កាលបរិច្ឆេទកំណត់ឱ្យដាក់លិខិតប្រកាសពន្ធ ឬបង់ប្រាក់ពន្ធដែលត្រូវចំថ្ងៃឈប់សំរាកប្រចាំសប្តាហ៍ ឬថ្ងៃឈប់សំរាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកិត្តិយស សូមជម្រាបជូនដំណឹងដល់អ្នកជាប់ពន្ធ និងសាធារណជនទាំងអស់ឱ្យបានជ្រាបថា ដើម្បីពង្រឹងការផ្តល់សេវាដល់អ្នកជាប់ពន្ធឱ្យកាន់តែប្រសើរ និងមានតម្លាភាព ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ កាលបរិច្ឆេទចុងក្រោយកំណត់ឱ្យដាក់លិខិតប្រកាសពន្ធ ឬបង់ប្រាក់ពន្ធដូចមានចែងក្នុងច្បាប់ និងបទបញ្ញត្តិនានាស្តីពីពន្ធដារ ដែលត្រូវចំថ្ងៃណាមួយនៃថ្ងៃឈប់សំរាកប្រចាំសប្តាហ៍ (ថ្ងៃសៅរ៍ ឬ អាទិត្យ) ឬថ្ងៃឈប់សំរាកស្របតាមប្រតិទិនឈប់សំរាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករនៅក្នុងព្រះរាជាណាចក្រកម្ពុជា កាលបរិច្ឆេទកំណត់ឱ្យដាក់លិខិតប្រកាសពន្ធ ឬបង់ប្រាក់ពន្ធនោះត្រូវលើកទៅថ្ងៃបន្ទាប់ដែលជាថ្ងៃធ្វើការ ។

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សង្ឃឹមជឿជាក់ថា ការកំណត់កាលបរិច្ឆេទដាក់លិខិតប្រកាសពន្ធ និងបង់ប្រាក់ពន្ធនេះ នឹងជួយសម្រួលដល់អ្នកជាប់ពន្ធទាំងអស់ ក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធជាក់ជាពុំខាន ។ ល

ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ

គង់ វិបុល

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
CORNER RUSSIAN FEDERATION & MAO TSETONG BLVD. TOEK LAAK 1, TOUL KAUK, PHNOM PENH
ទូរស័ព្ទ: (៨៥៥) ២៣ ៨៨៦ ៧០៨/ ទូរសារ: (៨៥៥) ២៣ ៨៨៦ ៧០០
Phone: (855) 23 886 708/ Fax: (885) 23 886 700